**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច ការងារ**

**បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**លេខ : ០១៧ សកបយ**

# សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមជូនដំណឹងដល់ សហព័ន្ធសហជីព សហជីពកម្មករនិយោជិត សមាគមនិយោជក និងនិយោជកនៃរោងចក្រសហគ្រាស ផ្នែកវាយនភ័ណ្ឌកាត់ដេរ និងដេរស្បែកជើងទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជាជ្រាបថា នៅថ្ងៃទី ១៣ ខែកក្កដា ឆ្នាំ ២០០០ គណៈកម្មការប្រឹក្សាការងារដែលមានតំណាងមកពីរាជរដ្ឋាភិបាល តំណាងមកពីខាងសហព័ន្ធសហជីព កម្មករនិយោជិត និងតំណាងមកពីខាងសមាគមនិយោជក បានធ្វើការប្រជុំពិភាក្សាគ្នាអំពីប្រាក់ឈ្នួលអប្បបរមារបស់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌកាត់ដេរ និងដេរស្បែកជើង ។ ការប្រជុំនោះសំរេចបានលទ្ធផលដូចតទៅ :-

១- យោងសភាពការណ៍ជាក់ស្តែងចំពោះមុខហើយ និងយោងតាមទឡ្ហីករណ៍ដែលលើកឡើងដោយតំណាងកម្មករនិយោជិត និងតំណាងនិយោជក ប្រាក់ឈ្នួលអប្បបរមាសំរាប់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌកាត់ដេរ និង ដេរស្បែកជើង គឺកំណត់ស្មើនឹង ៤០ ដុល្លារអាមេរិកក្នុងមួយខែ ក្នុងរយៈពេលដែលកម្មករនិយោជិតធ្វើការសាកល្បងការងារពី ១ ខែទៅ ៣ ខែ ។ ចំពោះកម្មករនិយោជិតដែលទទួលប្រាក់ឈ្នួលតាមបរិមាណផលិតផល (ដេរស៊ីបុង) ត្រូវបានប្រាក់ឈ្នួលតាមផលិតផលជាក់ស្តែងដែលធ្វើបាន ។ បើទិន្នផលការងារទទួលបានប្រាក់ឈ្នួលលើសពី ៤០ ដុល្លារអាមេរិកក្នុង ១ខែ គឺត្រូវទទួលតាមការលើសនោះ ។ តែបើបានទាបជាង ៤០ ដុល្លារអាមេរិកក្នុងមួយខែ និយោជកត្រូវបន្ថែមអោយគ្រប់ ៤០ ដុល្លារអាមេរិកក្នុងមួយខែ។

២- ចប់រយៈពេលសាកល្បង កម្មករ និយោជិត ដែលពេញសិទ្ធិហើយ គឺ ត្រូវទទួលបានប្រាក់ឈ្នួលអប្បបរមា ៤៥ ដុល្លារអាមេរិកក្នុងមួយខែ ។ ចំពោះកម្មករនិយោជិត ដែលទទួលប្រាក់ឈ្នួលតាមបរិមាណផលិតផល( ដេរស៊ីបុង ) ត្រូវបានប្រាក់ឈ្នួលតាមលទ្ធផលជាក់ស្តែងដែលធ្វើបាន ។ បើទិន្នផលការងារទទួលបានប្រាក់ឈ្នួលលើសពី ៤៥ ដុល្លារ អាមេរិកក្នុងមួយខែ គឺត្រូវទទួលតាមការលើសនោះ ។ តែបើបានទាបជាង ៤៥ ដុល្លារអាមេរិកក្នុងមួយខែ និយោជកត្រូវបន្ថែមអោយគ្រប់ ៤៥ ដុល្លារអាមេរិកក្នុងមួយខែ ។

៣- កម្មករនិយោជិត ដែលធ្វើការទៀងទាត់នៃចំនួនថ្ងៃដែលត្រូវធ្វើការក្នុងមួយខែៗនោះ ត្រូវបានប្រាក់រង្វាន់យ៉ាងតិចចំនួន ៥ ដុល្លារអាមេរិកក្នុងមួយខែ ។

៤- កម្មករនិយោជិត ដែលស្ម័គ្រចិត្តធ្វើការបន្ថែមម៉ោង តាមសំណូមពររបស់និយោជក ត្រូវទទួលបានប្រាក់ថ្លៃបាយចំនួន ១.០០០ រៀល ក្នុងមួយថ្ងៃ ឬទទួលបានការផ្តល់ជូនបាយមួយពេលដោយឥតគិតថ្លៃ ។

៥- កម្មករនិយោជិត ដែលធ្វើការបានយូរឆ្នាំនៅក្នុងរោងចក្រ សហគ្រាសណាមួយ ត្រូវបានប្រាក់រង្វាន់ការងារ ដូចតទៅ :-

៥.១- ធ្វើការបានចាប់ពីមួយឆ្នាំឡើងទៅ ត្រូវទទួលបានប្រាក់រង្វាន់អតីតភាពការងារចំនួន០២ ដុល្លារ អាមេរិកក្នុងមួយខែ ។

៥.២- ធ្វើការបានចាប់ពីពីរឆ្នាំឡើងទៅ ត្រូវទទួលប្រាក់រង្វាន់អតីតភាពការងារចំនួន ០៣ ដុល្លារអាមេរិកក្នុងមួយខែ ពោលគឺ ០២ ដុល្លារ នៃឆ្នាំទី ០១ បូកនិង ០១ ដុល្លារ នៃឆ្នាំទី ២ ។

៥.៣- ធ្វើការបានចាប់ពីបីឆ្នាំឡើងទៅ ត្រូវទទួលប្រាក់រង្វាន់អតីតភាពការងារចំនួន ០៤ ដុល្លារអាមេរិកក្នុងមួយខែ ពោលគឺ ០២ ដុល្លារ នៃឆ្នាំទី១ បូកនិង ១ដុល្លារ នៃឆ្នាំទី ២ បូកនិង ១ ដុល្លារ នៃឆ្នាំទី ៣ ។

៥.៤- ធ្វើការបានចាប់ពីបួនឆ្នាំឡើងទៅ ត្រូវទទួលប្រាក់រង្វាន់អតីតភាពការងារចំនួន ៥ ដុល្លារ អាមេរិកក្នុងមួយខែ ពោលគឺ ២ ដុល្លារនៃឆ្នាំទី ១ បូកនិង ១ ដុល្លារនៃឆ្នាំទី ២ បូកនិង ១ដុល្លារនៃឆ្នាំទី៣ បូក និង ១ ដុល្លារ នៃឆ្នាំទី ៤ ។

អតីតភាពសំរាប់គិតផ្តល់ប្រាក់រង្វាន់ខាងលើនេះត្រូវគិតចាប់ពីថ្ងៃទី០១ ខែ សីហា ឆ្នាំ ២០០០តទៅ។

៦- និយោជកត្រូវអនុញ្ញាតអោយកម្មករនិយោជិតឈប់សំរាកប្រចាំឆ្នាំអោយបានត្រឹមត្រូវតាមច្បាប់ស្តីពីការងារពោលគឺ កម្មករ និយោជិត ដែលធ្វើការបានទៀងទាត់ក្នុងរយៈពេល ១២ ខែ ត្រូវបានឈប់សំរាកប្រចាំឆ្នាំចំនួន ១៨ ថ្ងៃ។

ចាប់ពីថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០០ តទៅ ប្រាក់ឈ្នួលអប្បបរមា ប្រាក់រង្វាន់ការងារទៀងទាត់ ប្រាក់ថ្លៃបាយ ឬការផ្តល់ជូនបាយមួយពេល សំរាប់កម្មករនិយោជិតធ្វើការបន្ថែមម៉ោង និងប្រាក់រង្វាន់ការ-ងារយូរឆ្នាំរបស់កម្មករនិយោជិតផ្នែកវាយនភ័ណ្ឌកាត់ដេរ និងដេរស្បែកជើង ត្រូវអនុវត្តតាមខ្លឹមសារនៃចំណុចទាំងអស់ខាងលើ ។

ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងគណៈកម្មការប្រឹក្សាការងារនឹងបន្តខិតខំបំពេញនូវភារកិច្ចរបស់ខ្លួនអោយស្របតាមតួនាទី ដូចដែលមានចែងក្នុងច្បាប់របស់រដ្ឋ

ពិសេសគឺ ច្បាប់ស្តីពីការងារ សំដៅថែរក្សាផលប្រយោជន៍សមស្រប យុត្តិធម៌នៃរាល់ភាគីពាក់ព័ន្ធ ឱ្យកាន់តែល្អប្រសើរឡើងជាលំដាប់ ។

រាជធានីភ្នំពេញ , ថ្ងៃទី ១៨ ខែ កក្កដា ឆ្នាំ ២០០០

**រដ្ឋមន្ត្រី**

**ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា**

**ហត្ថលេខា និង ត្រា**

**អ៊ិត សំហេង**